**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមតុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៧៦
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២

# ដីកាបង្គាប់ឱ្យជូនដំណឹងជនជាប់ចោទ

## អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល

-បានឃើញ មាត្រា ៤៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
-បានឃើញ សេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការរបស់ប្រធានសភាព្រហ្មទណ្ឌ តុលាការកំពូល។

**បង្គាប់មក**
**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ**

ឱ្យជូនដំណឹងដល់ជនជាប់ចោទឈ្មោះ ផាង កៀង ហៅ ស្រី ភេទស្រី អាយុ៤០ ឆ្នាំ ជនជាតិខ្មែរ ។

**ជាប់ចោទពីបទ ៖** ការនាំចេញដោយមិនស្របច្បាប់សម្រាប់ការនាំឆ្លងដែន ប្រព្រឹត្តនៅ៖ ភូមិអូរឈើទាល ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

បច្ចុប្បន្នឃុំខ្លួននៅ ៖ ពន្ធនាគារខេត្តបាត់ដំបង ។

មកកាន់តុលាការកំពូលនៅ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ៨:00ព្រឹក ដើម្បីចូលរួមសវនាការ (សាលសវនាការលេខ២) រួចនាំខ្លួនទៅពន្ធនាគារវិញ។

**សមាសភាពអង្គជំនុំជម្រះរួមមាន៖**

លោកជំទាវ គិម សត្ថាវី ជាប្រធាន, ឯកឧត្តម ហេង ប្រីយា, ឯកឧត្តម គង់ តារាធាត, លោកជំទាវ សែម សក្តិកូឡា, ឯកឧត្តម សោម សិរីវុឌ្ឍ ជាចៅក្រមប្រឹក្សានៃក្រុមប្រឹក្សាជំនុំជម្រះ។

សំគាល់: *-សូមចូលមកតុលាការកំពូលឲ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើ។*
*-យកមកជាមួយនូវឯកសារផ្សេងៗដែលពាក់ព័ន្ធរឿងក្តីខាងលើ ប្រសិនបើមាន។*

ថ្ងៃចន្ទ ០៣រោច ខែបិស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣
**អគ្គព្រះរាជអាជ្ញារង**

**ឈួន ចាន់ថា**